## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជាបុណ្យចូលឆ្នាំខ្មែរនៅផ្សារតូច
## ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៨
## *តើអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទជាអ្វីខ្លះ?*

អត្ថបទទី១៖ កក ៦,១-៧
ដំណឹងល្អ៖ យហ ៦,១៦-២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះខ្ញុំទេសនាសម្រាប់ភូមិភាគភ្នំពេញទាំងមូល ដើម្បីផ្សព្វផ្សាយ ដើម្បីឲ្យព្រះសហគមន៍ គេអាចទទួលនិងស្តាប់នូវអ្វីដែលយើងចែករំលែក ដល់ព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគភ្នំពេញ។ ឆ្នាំថ្មី ដែលជាពេលវេលាមួយពិសេស សម្រាប់យើងដែលរស់នៅក្នុងប្រទេសកម្ពុជា និងឆ្នាំថ្មីនេះ ត្រូវថ្ងៃទី១៤ខែមេសាឆ្នាំ២០១៨។

នៅពេលយើងនិយាយដល់ថ្ងៃទី១៤ខែមេសា យើងនឹកឃើញភ្លាមដល់ថ្ងៃដែលលោកអភិបាលឆ្នាសាឡាស បានទទួលការតែងតាំងជាអភិបាល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។ នៅឆ្នាំនោះលោកឪពុកសាឡឹម បានធ្វើបុណ្យចម្លងចុងក្រោយជាមួយគ្រីស្តបរិស័ទនៅពោធិ៍ធំ នៅតាស្លូ នេះជាអ្វីដែលខ្ញុំបានស្តាប់លោកតាលោយាយផ្តល់សាក្ខីភាពប៉ុន្មានអាទិត្យមុន អំពីបុណ្យចម្លងចុងក្រោយ។ ដូច្នេះថ្ងៃនេះ យើងនឹករឭកដល់លោកអភិបាលប្រទេសកម្ពុជា ដែលបានទទួលតែងតាំងនៅក្នុងពេលវេលាយ៉ាងពិបាក ទោះបីបងប្អូនបង្កើត ទោះបីបងប្អូនរបស់គាត់បានចូលរួមយ៉ាងច្រើននៅក្នុងពិធីតែងតាំងនេះដែលធ្វើនៅព្រះវិហារព្រះមាតានៅជិតនេះ។ ប៉ុន្តែជាថ្ងៃដែលលោកអភិបាល បានទទួលឈើឆ្កាងនេះ ដែលយើងទុកជាសញ្ញាសម្គាល់នៃជីវិត ជាជីវិតពិសេសដែលបានបូជាសម្រាប់ព្រះជាម្ចាស់។ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩០ យើងនឹកឃើញដល់លោកអភិបាលអេមីល នៅពេលនោះដែលជាលោកឪពុក បានថ្វាយអភិបូជាលើកទីមួយបន្តពីសម័យប៉ុលពត បន្តពីសម័យទុក្ខលំបាកនៃប្រទេសកម្ពុជាទាំងមូល។ ពេលយើងនិយាយអំពីថ្ងៃទី១៤ ខែមេសា យើងនឹកដល់លោកអភិបាលអ៊ីវរ៉ាម៉ូស ដោយសារគាត់បានបញ្ចប់តួនាទីរបស់គាត់ទទួលខុសត្រូវភូមិភាគភ្នំពេញយ៉ាងពេញលក្ខណៈ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០១ លោកអភិបាលដែលបានបម្រើ ដែលបានស្រឡាញ់ព្រះសហគមន៍របស់យើងយ៉ាងខ្លាំង។ អាទិត្យមុន លោកអភិបាលបានសរសេរសំបុត្រមួយមកខ្ញុំ ដើម្បីជូនពរ ដើម្បីអរគុណ

ដោយសារខ្ញុំបានជូនពរគាត់ក្នុងឱកាសបុណ្យកំណើតគាត់នៅឆ្នាំនេះ អាយុ៩០ឆ្នាំ និង៥០ឆ្នាំជាងជាលោកអភិបាល ដែលពីរបីថ្ងៃមុនគាត់សរសេរសំបុត្រមួយ ដើម្បីអរគុណ និងដើម្បីជូនពរដល់ព្រះសហាគមន៍ប្រទេសកម្ពុជាទាំងមូល ដែលគាត់បន្តទុកនៅក្នុងដួងចិត្តរបស់គាត់ នៅក្នុងការអធិដ្ឋានរបស់គាត់។

ដូច្នេះនៅថ្ងៃនេះ ពិតមែនអធិដ្ឋានរបស់យើងជាគ្រីស្តបរិស័ទ ជាអធិដ្ឋានដែលយើងផ្ញើជូនដល់ព្រះជាម្ចាស់ សម្រាប់បងៗ បងប្រុស បងស្រី លោកអភិបាល មរណៈសាក្សី គ្រីស្តបរិស័ទ និងបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទដែរ ដែលបានទទួលមរណៈភាពនៅក្នុងសម័យប៉ុលពត។ ថ្ងៃនេះយើងអធិដ្ឋានដែរ សម្រាប់បងៗរបស់យើង ដែលបានជួយបន្តជំនឿរហូតមកដល់សព្វថ្ងៃ និងកំពុងបន្តធ្វើដំណើរជាមួយយើងនៅក្នុងបច្ចុប្បន្ននេះ។

ថ្ងៃនេះការអធិដ្ឋានរបស់ខ្ញុំ និងការអធិដ្ឋានរបស់បងប្អូន គឺដើម្បីជូនពរគ្នាទៅវិញទៅមក គឺជូនពរដល់ព្រះសហាគមន៍នីមួយៗក្នុងភូមិភាគភ្នំពេញ ជូនពរដល់គ្រីស្តបរិស័ទថ្មីៗ ជូនពរដល់គ្រីស្តបរិស័ទចាស់ៗ ជូនពរដល់គ្រីស្តបរិស័ទដែលនៅឆ្ងាយពីព្រះសហាគមន៍សព្វថ្ងៃ ជូនពរជាពិសេសដល់បងប្អូនដែលកំពុងឈ្វេងយល់ ស្វែងរកអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលកំពុងធ្វើដំណើរតាមព្រះពន្លឺរបស់ព្រះគ្រីស្ត។ ថ្ងៃនេះ ខ្ញុំគិតថាជាឱកាសមួយ សម្រាប់យើងដែលជាគ្រីស្តបរិស័ទខ្មែរ ដើម្បីបង្ហាញអំពីមោទនភាពរបស់យើងដែលជាគ្រីស្តបរិស័ទ។ យើងមានមោទនភាពសម្រាប់វប្បធម៌របស់យើង យើងមានមោទនភាពសម្រាប់ប្រទេសនិងអរិយធម៌របស់យើង យើងមានមោទនភាពសម្រាប់ប្រវត្តិសាស្ត្រដ៏ពិសេសនៃប្រទេសរបស់យើង។ ប៉ុន្តែយើងត្រូវតែមានមោទនភាពដែរ ដោយសារយើងជាគ្រីស្តបរិស័ទ យើងជាសាវ័ករបស់ព្រះគ្រីស្ត យើងជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ និងព្រះបិតាបានជ្រើសរើសយើង ដើម្បីឲ្យយើងធ្វើជាបុត្រធីតារបស់ព្រះអង្គ នេះជាមោទនភាពរបស់យើងដែរ។

ថ្ងៃនេះ ជាថ្ងៃមួយយ៉ាងពិសេសសម្រាប់គ្រីស្តបរិស័ទ សម្រាប់ព្រះសហាគមន៍នីមួយៗនៅក្នុងភូមិភាគរបស់យើង ដើម្បីទុកឲ្យព្រះជាម្ចាស់ប្រទានពរឲ្យយើង ទុកឲ្យព្រះជាម្ចាស់ប្រទានពរដល់គ្រួសាររបស់យើង ដល់ប្រទេសរបស់យើង។ នៅថ្ងៃនេះ ខ្ញុំសង្ឃឹមនៅតាមព្រះវិហារនីមួយៗ មានអភិបូជាកុំឲ្យយើងគិតថា ថ្ងៃស្អែកជាថ្ងៃអាទិត្យឲ្យយើងធ្វើ

ថ្ងៃអាទិត្យទៅ! ថ្ងៃនេះជាថ្ងៃចូលឆ្នាំទីមួយ ដូច្នេះជាថ្ងៃសំខាន់ជាពិសេសនៅក្នុងព្រះសហគមន៍ថ្មីៗ ទោះបីមានគ្រីស្តបរិស័ទតែមួយឬពីរក៏ដោយ យើងមានយុវជនខ្លះ យើងមានកូនក្មេងខ្លះ។ ខ្ញុំសង្ឃឹមថ្ងៃនេះ នៅគ្រប់ព្រះសហគមន៍ជាពិសេសនៅព្រះសហគមន៍ថ្មីនៅក្នុងខេត្តកំពត នៅក្នុងខេត្តតាកែវ ឬនៅក្នុងខេត្តនានាដែលទើបនឹងបង្កើតថ្មីៗ ទោះបីអត់ទាន់មានគ្រីស្តបរិស័ទ ប៉ុន្តែថ្ងៃនេះយើងជួបជុំគ្នា ដើម្បីអធិដ្ឋាននិងជាពិសេសដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គប្រទានពរដល់យើងរៀងៗខ្លួន ដល់គ្រួសារយើង ដល់ប្រទេសរបស់យើង ដល់ជំនឿរបស់យើង ដល់ជីវិតរបស់យើង។ យើងមិនមែនជាជនជាតិខ្មែរម្នាក់ ដែលមានគ្រួសារ ដែលមិនមែនជាគ្រីស្តបរិស័ទ ដែលធ្វើការ ដែលទៅសាលា ដែលរស់នៅក្នុងភូមិ រស់នៅក្នុងទីក្រុង នៅក្នុងខណ្ឌឬសង្កាត់មួយ និងយូរៗម្តងយើងចូលព្រះវិហារនៅពេលនោះយើងជាគ្រីស្ត។ អ្វីៗដែលសំខាន់បំផុត នៅក្នុងថ្ងៃនេះជាថ្ងៃទីមួយនៃពិធីចូលឆ្នាំប្រពៃណីហាក់បីដូចជានៅថ្ងៃភ្ជុំបិណ្ឌ យើងធ្វើយ៉ាងម៉េចសម្រាប់យើងដែលជាព្រះសហគមន៍កាតូលិកកម្ពុជា បង្ហាញអំពីអត្តសញ្ញាណរបស់យើង ជាជនជាតិខ្មែរដែលមានជំនឿលើព្រះយេស៊ូគ្រីស្ត ជំនឿរបស់យើងនិងជីវិតរបស់យើង ជាប្រចាំរបស់យើងចូលគ្នាដើម្បីធ្វើដំណើររួមជាមួយគ្នាដោយសារយើងជាមនុស្សតែមួយ។ នៅថ្ងៃដែលយើងបានទទួលអត្តសញ្ញាជ្រមុជទឹក យើងចាំនៅថ្ងៃហ្នឹងយើងបានទទួលអាវស ជាសញ្ញាសម្គាល់ថាយើងបំពាក់ព្រះយេស៊ូអស់មួយជីវិត។ អាវសទោះបីយើងដោះចេញពេលយើងទៅដល់ផ្ទះ ប៉ុន្តែយើងបានបំពាក់ព្រះយេស៊ូតាមអត្តសញ្ញាជ្រមុជទឹក យើងដោះព្រះយេស៊ូចេញពីខ្លួនរបស់យើងអត់បានទេ។ ព្រះយេស៊ូ ភ្ជាប់ជាមួយយើងអស់ហើយ យើងធ្វើយ៉ាងម៉េចដើម្បីឲ្យនៅថ្ងៃបុណ្យតាមប្រពៃណីខ្មែរ យើងអាចមានពិធីបុណ្យដែលណែនាំឲ្យយើងទទួលព្រះពរពីព្រះជាម្ចាស់។ នៅពេលនេះខ្ញុំនិយាយដល់លោកឪពុកនៅក្នុងភូមិភាគភ្នំពេញទាំងមូល ជាពិសេសដល់ព្រះសហគមន៍ថ្មីៗ ឲ្យធ្វើយ៉ាងម៉េចដើម្បីយកចិត្តទុកដាក់ដើម្បីយល់អំពីប្រពៃណីវប្បធម៌ ស្រឡាញ់វប្បធម៌និងអរិយធម៌របស់យើង ដើម្បីឲ្យជំនឿរបស់យើងចូលគ្នាតែមួយ នៅក្នុងដួងចិត្តរបស់គ្រីស្តបរិស័ទយើង កុំឲ្យយើងគិតអំពីជីវិតនៅក្នុងសាសនា និងជីវិតសង្គមជាជីវិតពីរ យើងជាគ្រីស្តបរិស័ទតែមួយ។ ពិតមែន យើងមានមោទនភាពដោយសារយើងជាជនជាតិខ្មែរ តែជាជនជាតិខ្មែរដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីទទួលអត្តសញ្ញាជ្រមុជទឹក ដើម្បីទទួលជីវិត។ យើងរួមគ្នា យើងបង្កើតជីវិតរបស់យើងដោយយល់ថាជីវិតមានតម្លៃ និងវប្បធម៌ អរិយធម៌របស់យើងមានតម្លៃ ឲ្យយើងរួមគ្នាតែ

មួយដើម្បីកោតសរសើរព្រះជាម្ចាស់ និងទូលអង្វរដល់ព្រះអង្គឲ្យព្រះអង្គប្រទានពរដល់យើង ដើម្បីឲ្យឆ្នាំថ្មីនេះយើងពោរពេញដោយសេចក្តីសុខសាន្ត និងពោរពេញដោយជីវិតដោយសារព្រះជាម្ចាស់ ជាម្ចាស់នៃជីវិតរបស់យើង។

បងប្អូនជាទីស្រឡាញ់!

យើងបានស្តាប់អំពីធម្មទេសនាដំបូងបង្អស់របស់ព្រះយេស៊ូ ដែលណែនាំឲ្យយើងស្តាប់អំពីសុភមង្គលដ៏ពិតប្រាកដ។ ពិតមែនជារៀងរាល់ឆ្នាំមានយើងស្តាប់អត្ថបទនេះ ជាឱកាសមួយម្តងទៀត ដើម្បីទទួលព្រះពរពីព្រះជាម្ចាស់ ដោយសារជីវិតរបស់យើងត្រូវការព្រះពរច្រើនណាស់។ នៅពេលលាគ្នា លោកសង្ឃមានដីកាថា "ចម្រើនពរ"។ ប៉ុន្មានអាទិត្យមុនខ្ញុំនិយាយពាក្យនេះ គេថាខ្ញុំមិនមែនលោកសង្ឃនិយាយពាក្យនេះយ៉ាងនេះម្តេចបាន? ប៉ុន្តែយើងដឹងថានិយាយក៏បានដែរ ដោយសារយើងពោរពេញដោយព្រះពរពីព្រះជាម្ចាស់។ យើងចង់ឲ្យនៅក្នុងជីវិតយើង ព្រះពររីកចម្រើនថែមទៀត "ចម្រើនពរ" ជាឱកាសមួយនៅក្នុងចូលឆ្នាំថ្មីនេះ។ នៅពេលយើងស្តាប់ធម្មទេសនារបស់ព្រះយេស៊ូ សេចក្តីប្រកាសរបស់ព្រះយេស៊ូអំពីសុភមង្គលដ៏ពិតប្រាកដ យើងយល់ថា ជីវិតរបស់យើងគឺដើម្បីទទួលសុភមង្គល ជីវិតរបស់យើងគឺដើម្បីឲ្យយើងទាំងអស់ទៅជាមនុស្សដ៏វិសុទ្ធដូចព្រះជាម្ចាស់។ ថ្ងៃនេះជាឱកាសមួយល្អ ដើម្បីនិយាយអំពីជីវិតដ៏វិសុទ្ធរបស់យើង ដោយសារថ្ងៃច័ន្ទក្នុងអាទិត្យនេះ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសរសេរសារលិខិតថ្មីមួយ ជូនដល់គ្រីស្តបរិស័ទទាំងអស់ ដល់លោកបូជាចារ្យ ដល់លោកអភិបាលនៅលើពិភពលោកទាំងមូល ដែលមានចំណងជើងថា **"អំណរសប្បាយ និងការសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់"** ដើម្បីណែនាំឲ្យគ្រីស្តបរិស័ទទាំងឡាយទៅជាមនុស្សដ៏វិសុទ្ធដូចព្រះជាម្ចាស់។ ពិតមែនប្រសិនបើយើងគិត នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ សង្គមដែលកំពុងរីកចម្រើនយ៉ាងលឿនបំផុត **តើអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទជាអ្វីខ្លះ? តើយើងធ្វើដូចម្តេចដើម្បីប្រកាសដល់បងប្អូនឯទៀតៗ អំពីព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញ?** ដោយសារជំនឿរបស់យើងមិនមែនលើព្រះយេស៊ូប្រសូត ជំនឿរបស់យើងមិនមែនលើព្រះយេស៊ូសោយទិវង្គត ជំនឿរបស់យើងគឺលើព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ប្រសិនបើព្រះយេស៊ូបានប្រសូតតែប៉ុណ្ណឹង និងសោយទិវង្គតតែប៉ុណ្ណឹង យើងមិនអាចអង្គុយនៅទីនេះទេ។ ប៉ុន្តែព្រះយេស៊ូបានប្រសូត ព្រះយេស៊ូបានសោយទិវង្គត និងព្រះយេស៊ូមានព្រះជន្ម

រស់ឡើងវិញ ហើយនេះជាជំនឿរបស់យើង។ ព្រះយេស៊ូប្រសូតម្យ៉ាងអត់ត្រូវការមានជំនឿទេ ដោយសារនេះជាប្រវត្តិសាស្ត្រ នៅក្នុងសម័យស្តេចហេរ៉ូដ ព្រះចៅអធិរាជអហ្គូស នៅភូមិបេថ្លេហឹមមានក្មេងដែលជារាជវង្សព្រះបាទដាវីឌបានប្រសូត នេះជាប្រវត្តិសាស្ត្រ អត់មាននរណានិយាយថាអត់កើតឡើងទេ។ ប៉ុន្តែនេះពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នេះមិនមែនប្រវត្តិសាស្ត្រ មិនមែនថ្ងៃប៉ុន្មាន? ឆ្នាំប៉ុន្មាន? គឺផ្នែកនៃជំនឿដែលអាចទទួលបាន និងជំនឿរបស់យើងគឺទីពឹងលើព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ យើងជាគ្រីស្តបរិស័ទដោយសារយើងជឿសង្ឃឹមថា ព្រះយេស៊ូពិតមែនមានព្រះជន្មរស់ឡើងវិញ យើងនិយាយថាយើងផ្ញើជីវិតរបស់យើងទាំងស្រុងលើព្រះជាម្ចាស់ មូលហេតុមួយ ដោយសារយើងជឿថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ដូច្នេះសម្រាប់យើងជាគ្រីស្តបរិស័ទខ្មែរ យើងធ្វើយ៉ាងម៉េចសព្វថ្ងៃ ដើម្បីបង្ហាញយ៉ាងជាក់ស្តែងដល់បងប្អូនឯទៀតៗថាពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ? ប្រសិនបើយើងបានស្តាប់អត្ថបទកិច្ចការគ្រីស្តទូតនៅក្នុងប៉ុន្មានថ្ងៃកន្លងមក យើងឃើញលោកសិលាដែលខិតខំពន្យល់ទៅលោកទីប្រឹក្សាជាន់ខ្ពស់នៃសាសនាយូដាអំពី "ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ" ពិបាកពន្យល់ គេទទួលមិនបាន។ យើងឃើញលោកប៉ូលដែលខិតខំនិយាយអំពីលោកយេស៊ូ ដែលបានធ្វើនេះធ្វើនោះ ប៉ុន្តែពេលដែលគាត់និយាយទៅដល់រឿងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដល់អ្នកទស្សនវិជ្ជានៅទីក្រុងអាថែន ប្រទេសក្រិក នៅពេលនោះគេថានិយាយអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ គេមិនចង់ស្តាប់ទៅវិញ។ ដូច្នេះសម្រាប់យើងសព្វថ្ងៃយើងត្រូវការគិតពិចារណា៖ យើងធ្វើយ៉ាងម៉េចដើម្បីបង្ហាញនៅក្នុងជីវិតរបស់យើងជាក់ស្តែង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ? ខ្ញុំធ្វើយ៉ាងម៉េចដើម្បីបង្ហាញផ្លូវនៃជីវិតរបស់ខ្ញុំ គឺផ្លូវនៃជីវិតអស់កល្បជានិច្ច ដោយសារព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យយើងទទួលការសង្គ្រោះ។

ដូច្នេះជីវិតរបស់យើងជាគ្រីស្តបរិស័ទ គឺ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូប្រទានឲ្យខ្ញុំមានជីវិតអស់កល្បជានិច្ច និងនៅលើផែនដីនេះខ្ញុំរស់នៅជាប្រចាំថ្ងៃដើម្បីរៀបចំខ្លួនទទួលជីវិត និងទទួលការសង្គ្រោះ។ ដូច្នេះប្រហែលមុននិយាយយើងត្រូវការរៀបចំចិត្តគំនិត និងថ្ងៃនេះខ្ញុំចេញ៥ចំណុចដែលមកពីសារលិខិតថ្មីរបស់សម្តេចប៉ាប។

**ទីមួយ** ឥលូវនេះយើងនិយាយអំពីឥរិយាបទនៃជីវិតរបស់យើង នៃការប្រើវិញ្ញាណនៅក្នុងដួងចិត្តរបស់យើង។ មុនយើងអនុវត្ត មុនយើងនិយាយ មុនយើងផ្តល់សាក្សីភាព កែប្រែចិត្តគំនិតរបស់យើង។ ទីមួយ ដើម្បីកែប្រែចិត្តគំនិតគឺ ឲ្យយើងមានចិត្តអត់ធ្មត់ និងតស៊ូ។ ជីវិតយើងជាគ្រីស្តបរិស័ទ ជាការតស៊ូ។ គ្រីស្តបរិស័ទចាស់ៗគេដឹងហើយ ប៉ុន្តែគ្រីស្តបរិស័ទថ្មីៗជូនកាលសង្គមរបស់យើង លែងណែនាំឲ្យយើងតស៊ូអស់។ ប៉ុន្តែជំនឿ ដើម្បីទៅជាអ្នកដ៏វិសុទ្ធ ណែនាំឲ្យយើងតស៊ូ តស៊ូនៅក្នុងជីវិតយើង។ ព្រះយេស៊ូបានលីឈើឆ្កាងមុនជីវិតថ្មី ព្រះយេស៊ូបានរងទុក្ខលំបាកមុនពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ការតស៊ូ និងចិត្តអត់ធ្មត់ យើងមិនអាចមានភ្លាមៗ ជីវិតរបស់យើងទោះបីកែ ជាមូលហេតុពីមួយឆ្នាំទៅមួយឆ្នាំ យើងមានរដូវបុណ្យចម្លង រដូវរង់ចាំ រដូវ៤០ថ្ងៃ រដូវបុណ្យព្រះយេស៊ូប្រសូត ដើម្បីណែនាំឲ្យយើងមានចិត្តអត់ធ្មត់ និងចិត្តតស៊ូ ដើម្បីរៀបចំចិត្តគំនិត មិនមែនដដែលៗ ដោយធ្វើជាមនុស្សថ្មីគ្រប់វិនាទី ដូច្នេះយើងមានពេលនៅក្នុងជីវិតរបស់យើង។

**ទីពីរ** គឺឲ្យយើងពោរពេញដោយអំណរសប្បាយដូចព្រះនាងម៉ារី ដែលទទួលដំណឹងល្អពីទេវទូតកាព្រីអ៊ែល ចែករំលែកជាមួយលោកយាយអេលីសាប៊ែតភ្លាមៗ ពោរពេញដោយអំណរសប្បាយ។ គ្រីស្តបរិស័ទ ជាមនុស្សម្នាក់ដែលបង្ហាញអំពីអំណរសប្បាយ ប៉ុន្តែមិនមែនអំណរសប្បាយដោយសារយើងទៅដើរលេង ជាអំណរសប្បាយដែលចូលយ៉ាងជ្រៅ មិនមែនអំណរសប្បាយតាមថ្ងៃនេះអារម្មណ៍ខ្ញុំសប្បាយឬមិនសប្បាយ តែគឺអំណរសប្បាយដ៏ពេញលក្ខណៈដែលមកពីព្រះយេស៊ូ។

**ទីបី** ឲ្យយើងមានចិត្តក្លាហាន ចិត្តក្លាហានដើម្បីប្រកាសដំណឹងល្អ និងប្រកាសដំណឹងល្អដោយយកចិត្តទុកដាក់។ លោកប៉ូល គាត់និយាយហើយ "**ខ្ញុំខ្មាសណាស់ប្រសិនបើខ្ញុំមិនទៅប្រកាសដំណឹងល្អ**"។ តួនាទីរបស់យើងជាគ្រីស្តបរិស័ទ យើងត្រូវការមានសេចក្តីក្លាហានដើម្បីបង្ហាញអំពីជំនឿរបស់យើង ដើម្បីបង្ហាញអំពីជីវិតដែលយើងបានទទួលនៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង។ កុំឲ្យយើងលាក់យើងជាគ្រីស្តបរិស័ទ ពេលយើងរៀនតាមសាកលវិទ្យាល័យនានា យើងធ្វើការនៅកន្លែងនានា ជីវិតរបស់យើងជាគ្រីស្តបរិស័ទ យើងមានមោទនភាព សេចក្តីក្លាហាន និងការយកចិត្តទុកដាក់។

**ទីបួន** ជីវិតយើងជាគ្រីស្តបរិស័ទ មិនមែនជាជីវិតម្នាក់ឯង ឯកោ យើងមិនអាចទៅមុខ ប្រសិនបើយើងនៅម្នាក់ឯង។ គ្រីស្តបរិស័ទ រស់នៅជាគ្រីស្តបរិស័ទពិតប្រាកដនៅពេលយើងរស់នៅក្នុងព្រះសហគមន៍។ យើងមិនអាចថា យើងជាគ្រីស្តបរិស័ទម្នាក់ឯងនៅក្នុងផ្ទះរបស់យើង អត់ដែលចូលព្រះវិហារ អត់ដែលស្គាល់គ្រីស្តបរិស័ទដទៃ អត់ដែលជួបជុំគ្នាដើម្បីជួយបងប្អូនឯទៀតៗ។ គ្រីស្តបរិស័ទរស់នៅដើម្បីធ្វើជាអ្នកដ៏វិសុទ្ធ នៅក្នុងព្រះសហគមន៍ ព្រះសហគមន៍ដែលប្រទានអគ្គសញ្ញានានា ព្រះសហគមន៍ដែលជាសហគមន៍មួយដូចបងប្អូនបង្កើត ដែលជួយគ្នាទៅវិញទៅមក និងគ្រប់គ្រីស្តបរិស័ទថ្មីៗ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកពីមួយឆ្នាំទៅមួយឆ្នាំ គេចូលនៅក្នុងសាសនារបស់យើង គេមានជំនឿលើព្រះយេស៊ូ ដោយសារគេរកឃើញគ្រួសារមួយ មិនមែនដោយសារគេមានជំនឿលើព្រះជាម្ចាស់ផ្ទាល់ ដែលអត់ចាប់អារម្មណ៍ពីសហគមន៍នៃគ្រីស្តបរិស័ទ។ យើងជាសហគមន៍ ប៉ុន្តែមិនមែនជាសហគមន៍ធម្មតា យើងជាសហគមន៍ដែលព្រះជាម្ចាស់ត្រាស់ហៅ មានន័យថា "**ព្រះសហគមន៍**"។

**ទីប្រាំ** យើងត្រូវការអធិដ្ឋានជានិច្ច ប្រសិនបើយើងចង់តស៊ូ និងមានចិត្តអត់ធ្មត់ យើងចង់ពោរពេញដោយអំណរសប្បាយ យើងចង់រស់នៅក្នុងព្រះសហគមន៍ជាគ្រួសារតែមួយ យើងត្រូវការថែរក្សាជីវិតអធិដ្ឋាន។ អត់មានអធិដ្ឋាន អត់មានអីសោះ! ដូច្នេះសូមអធិដ្ឋាន សូត្រធម៌ឱព្រះបិតាខ្លះ សូត្រផ្គាំខ្លះ ចូលវិហារស្តាប់គម្ពីរ ចូលតាំងព្រះកាយ។ អម្បាញ់មិញយើងនឹកដល់លោក ឆ្មា សាឡាស នៅក្នុងសម័យប៉ុលពត តើគ្រីស្តបរិស័ទយើងនៅសល់អី? តាមពិតនៅពេលនោះព្រះសហគមន៍ជួបជុំគ្នាអត់បាន នៅពេលនោះយើងមិនអាចរស់នៅលើកទឹកចិត្តឲ្យគ្នាទៅវិញទៅមក អត់មានអភិបូជា អត់មានបូជាចារ្យបងស្រីដើម្បីបម្រើយើង តែយើងនៅសល់អធិដ្ឋានតែប៉ុណ្ណឹង អធិដ្ឋានស្ងាត់ៗ បពិត្រព្រះនាងម៉ារីមួយ ឱព្រះបិតាមួយ ទោះបីគេបង្ខំយើងឲ្យធ្វើស្រែ កាយដីនៅខ្លែងក្តៅ នៅតាមផ្លូវយើងនៅសល់តែអធិដ្ឋាន។ ពេលយើងបានរៀបចំខ្លួនរបស់យើង ដើម្បីបង្ហាញយ៉ាងជាក់ស្តែងដល់សង្គមរបស់យើង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នេះជារបៀបដែលត្រូវការបើកភ្នែក របៀបលោកីយ៍ និងរបៀបព្រះជាម្ចាស់។ យើងរស់នៅក្នុងលោកីយ៍ យើងរវីរវល់នឹងរឿងលោកីយ៍ ព្រះយេស៊ូមកពីស្ថានបរមសុខ ណែនាំឲ្យជីវិតរបស់យើងភ្ជាប់ជាមួយជីវិតរបស់ព្រះយេស៊ូផង ភ្ជាប់ជាមួយលោកកីយ៍ផង និងយើងធ្វើយ៉ាងម៉េចដើម្បីឲ្យជីវិត

របស់យើងមានភ្នែករបស់ព្រះយេស៊ូ ដើម្បីកែច្នៃសង្គមរបស់យើងសព្វថ្ងៃ? អត់ពិបាកប៉ុន្មានទេ ប៉ុន្តែស៊ីសងយើង មានន័យថា ប្រសិនបើយើងបិទភ្នែកយើងអត់ឃើញអីសោះ។ ដូច្នេះពេលយើងបើកភ្នែក យើងឃើញ នៅពេលមានចិត្តចង្អៀតចង្អល់ ពេលមានចិត្តអាត្មានិយម យើងធ្វើយ៉ាងម៉េចដើម្បីបង្ហាញអំពីចិត្តទូលំទូលាយ ដែលយកចិត្តទុកដាក់ចំពោះអ្នកដទៃ? នៅពេលមានអំពើហិង្សា និងការស្អប់គ្នា យើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងទៅជាអ្នកដែលមានសម្ដីដែលណែនាំការលើកលែងទោស និងណែនាំសេចក្ដីសុខសាន្ត? នៅពេលមានមនុស្សដែលរស់នៅឯកោ រស់សម្រាប់ខ្លួនឯងតែប៉ុណ្ណឹង អត់ចេះបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ យើងធ្វើយ៉ាងម៉េចដើម្បីទៅជាសញ្ញាសម្គាល់ នៃភាតរភាពជាបងប្អូនគ្នាពិតៗ? នៅពេលមានមនុស្សដែលមើលងាយអ្នកតូចតាច អ្នកក្រីក្រ អ្នកដែលទុរគត កូនក្មេងដែលអនាថា អ្នកដែលគ្មានទីពឹង អ្នកជំងឺអេដស៍ អ្នកពិការ យើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងមានចិត្តអាណិតមេត្តាពិតមែន? នៅពេលយើងជួបមនុស្សដែលមានតែគំនិតងងឹត គំនិតដែលចេះតែព្រួយបារម្ភ ដែលមើលតែភាពអវិជ្ជមាន តើយើងធ្វើយ៉ាងម៉េចដើម្បីទៅជាសញ្ញាសម្គាល់នៃអំណរសប្បាយពិតៗ? នៅពេលជួបជាមួយមនុស្ស ដែលចេះតែនិយាយកុហកដែលមានចិត្តទុច្ចរិត ដែលអត់ចេះគោរពយុត្តិធម៌ ដែលពោរពេញដោយចិត្តពុករលួយ ដែលអត់មានចិត្តស្មោះត្រង់ យើងធ្វើយ៉ាងម៉េចយើងជាគ្រីស្តបរិស័ទ ដើម្បីមានចិត្តស្មោះត្រង់ និងចិត្តដែលបង្ហាញអំពីសេចក្ដីពិត? នៅពេលដែលយើងជួបជាមួយមនុស្សដែលមិនគោរពថែរក្សាបរិស្ថាន និងធម្មជាតិដែលយើងបានទទួលជាព្រះអំណោយទានពីព្រះជាម្ចាស់ ដែលមិនគោរពជីវិតរបស់អ្នកដទៃ យើងយ៉ាងម៉េចដើម្បីបង្ហាញថាតម្លៃថ្លៃថ្នូរនៃជីវិតមានតម្លៃលើសអ្វីៗទាំងអស់? ដោយសារនៅពេលយើងសម្រេចចិត្តអ្វីខ្លះឲ្យយើងដាក់មនុស្សនៅកណ្ដាលជាអាទិភាពសម្រាប់ការសម្រេចចិត្ត ដែលមនុស្សនេះមានតម្លៃថ្លៃថ្នូរ តើជីវិតរបស់គាត់អាចទៅមុខឬអត់?

នៅក្នុងពីរអាទិត្យកន្លងមក ខ្ញុំបានឃើញជាក់ស្ដែង ព្រះជាម្ចាស់បានលើកព្រះយេស៊ូឲ្យមានជីវិតថ្មី ព្រះជាម្ចាស់បានតែងតាំងព្រះយេស៊ូជាព្រះអម្ចាស់នៃជីវិត។ ព្រះជាម្ចាស់បានណែនាំឲ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿងយ៉ាងពិតប្រាកដ។ នេះខ្ញុំឃើញយ៉ាងជាក់ស្ដែង នៅពេលណាបងប្អូន? រៀងៗខ្លួនឲ្យគិតខ្លួនឯង។ នៅពេលយើងធ្វើពិធីបុណ្យជ្រមុជទឹកនៅយប់បុណ្យចម្លង នៅភូមិភាគភ្នំពេញ ជាង៨០នាក់ និងទូទាំងប្រទេសកម្ពុជា

ប្រហែល១៥០នាក់។ នៅពេលនោះយើងឃើញជាក់ស្តែង យុវជន ឬយុវចាស់ ដែលពោរពេញដោយអំណរសប្បាយដោយសារ បានទទួលជីវិតថ្មី នៅពេលនោះយើងឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ អាទិត្យមុន យើងបានសម្ពោធមហោស្រពសិល្បៈនៅភូមិចំការទៀង នៅពេលនោះខ្ញុំឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដោយសារតាមរយៈសិល្បៈ យើងបានប្រមូលមនុស្សជាច្រើន មានន័យថាយើងបានប្រមូលទាំងភូមិភាគបាត់ដំបង ទាំងភូមិភាគភ្នំពេញ ទាំងភូមិភាគកំពង់ចាម មណ្ឌលគីរី ជ្រៃធំ ដើម្បីសម្តែងសិល្បៈរួមជាមួយប្រជាជន រួមជាមួយអាជ្ញាធរដី និងរួមជាមួយតំណាងរបស់រាជរដ្ឋាភិបាលយើង។ ដូច្នេះនៅពេលយើងឃើញអ្វីៗទាំងអស់ក្នុងរយៈពេល៦ម៉ោង យើងជាគ្រួសារតែមួយ ដែលប្រមូលមនុស្ស ដែលជាទូទៅមិននៅជាមួយគ្នា ទាំងជនជាតិព្នង ទាំងម៉ុងសាយពីជ្រៃធំ ទាំងក្រុមសិល្បៈ របាំ រៀមកេរ្តិ៍ ត្រុដិ របាំផ្សេងៗ ទាំងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាំងមេភូមិ មេឃុំ អភិបាលស្រុក មន្ទីរ ប៉ូលីស ទាំងសិស្សសាលា ទាំងឪពុកម្តាយ ទាំងមនុស្សធម្មតា ទាំងគ្រីស្តបរិស័ទមកពីព្រះសហគមន៍ភូមិភាគភ្នំពេញទាំងមូល។ នៅពេលនោះយើងឃើញជាក់ស្តែងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ យើងបានរស់នៅ៦ម៉ោងរួមជាមួយគ្នាក្នុងអំណរសប្បាយនៃព្រះយេស៊ូជាជីវិត។ អាទិត្យមុនខ្ញុំបានឃើញមួយទៀត គឺមាននិស្សិតមកពីវិទ្យាស្ថានសន្តប៉ូល ដែលបានចូលរួមនៅក្នុងការប្រកួតប្រជែងជាមួយសាកលវិទ្យាល័យទាំង៦ ដើម្បីដណ្តើមយកពានរង្វាន់ត្នោតមាស ដើម្បីបង្ហាញថាយើងធ្វើយ៉ាងម៉េចដើម្បីកែច្នៃដើមចេកទាំងមូលឲ្យជួយអភិវឌ្ឍន៍ជនបទ និងជួយអ្នកក្រីក្រ។ ក្រុមដែលបានឈ្នះលេខ១គឺស្កុរគ្រាប់ដូង គឺក្រុមដែលបានកែច្នៃផ្លែចេកជាស្កុរគ្រាប់ដូង ដើមចេកជាក្រដាស ជាតែ ជាតម្រង់ចម្រោះទឹកស្អាត...។ ខ្ញុំឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដោយសារនិស្សិត និងបងប្អូនដែលធ្វើការនៅរោងចក្រស្កុរគ្រាប់ជាអ្នកក្រីក្រ និងគេមានសមត្ថភាពនៅក្នុងការរស់នៅដោយកម្លាំងរបស់គេ ដោយការងាររបស់គេដើម្បីទៅមុខ។ នេះប្រហែលយើងអាចបន្តទៅដល់ប៉ុន្មានកន្លែងក្នុងប្រទេសកម្ពុជា ដើម្បីណែនាំឲ្យអ្នកក្រីក្រមានជីវិតដោយការងាររបស់គេផ្ទាល់។ ប៉ុន្មានថ្ងៃមុនខ្ញុំទៅកោះស្លាជាមួយមេក្រុមកាយរិទ្ធិចំនួន១៥០នាក់ កូនក្រុមកាយរិទ្ធិប្រមាណជាង៥០០នាក់ ទៅបោះជំរំ៣ថ្ងៃ គេទៅជាមួយអ្នកក្រីក្រ គេសប្បាយជាមួយគ្នាផង គេច្រៀង គេជួយគ្នាទៅវិញទៅមក។ យើងឃើញជីវិតថ្មីដែលព្រះយេស៊ូបានប្រទានយ៉ាងជាក់ស្តែង។ យើងឃើញ ប៉ុន្មានថ្ងៃមុនក្រុមសង្គហៈព្រះសហគមន៍ផ្សារតូច បានជួយប៉ុន្មានរយនាក់នៅក្នុងឱកាសបុណ្យព្រះជាម្ចាស់

មានព្រះហឫទ័យមេត្តាករុណាដល់មនុស្សលោក។ ដូច្នេះមានឧទាហរណ៍ច្រើន ដែលយើងឃើញយ៉ាងជាក់ស្តែង ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

បងប្អូនជាទីស្រឡាញ់!

ឲ្យយើងអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើងនៅថ្ងៃនេះ យើងមិនគិតតែអំពីទេវតាដែលចុះ ប៉ុន្តែយើងគិតអំពីព្រះជាម្ចាស់ដែលយាងមក ដើម្បីប្រទានពរឲ្យព្រះសហគមន៍របស់យើង។ យើងអធិដ្ឋានសម្រាប់ប្រទេសរបស់យើង ដែលកំពុងរៀបចំការបោះឆ្នោតនៅថ្ងៃខាងមុខ ដើម្បីឲ្យយើងរកឃើញសេចក្តីសុខ និងបន្តមានសុខដុមរមនានៅក្នុងប្រទេសយើងទាំងមូល។ យើងទូលអង្វរ សូមឲ្យព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់ ដើម្បីឲ្យយើងទទួលទឹកភ្លៀងមួយយ៉ាងពិសេស ទឹកភ្លៀងដែលមិនធ្វើដោយទឹកភ្នែករបស់ព្រះជាម្ចាស់ ប៉ុន្តែទឹកភ្លៀងដែលធ្វើដោយផ្ការំដួលនិងផ្កាម្លិះ ដើម្បីឲ្យធ្លាក់មកលើយើង ដើម្បីឲ្យដួងចិត្តរបស់យើងបើកទូលំទូលាយ ដើម្បីឲ្យយើងចេះមើលឃើញសេចក្តីពិត និងភាពស្អាត ឲ្យយើងចេះមើលឃើញព្រះជាម្ចាស់ ដែលមានព្រះជន្មរស់ឡើងវិញនៅក្នុងជីវិតយើង នៅក្នុងប្រទេសកម្ពុជាយើង។ ជយោ ឆ្នាំថ្មី! អាម៉ែន៕